- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករាឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិនៃធនាគារជាតិនៃកម្ពុជា
- តាមសំណើរបស់អគ្គទេសាភិបាលធនាគាជាតិកម្ពុជា ។

**សំរេច**

**មាត្រា១.-** អនុញ្ញាតឱ្យចេញផ្សាយ ធ្វើចរាចរនិងប្រើប្រាស់ក្នុងទូទាំងព្រះរាជានាចក្រកម្ពុជា នូវក្រដាសប្រាក់ ៥ ០០០រៀល- ១០.០០០រៀល និង ៥០.០០០រៀល គំរូថ្មី ទន្ទឹម និងប្រភេទប្រាក់ដែល មាន ចេញផ្សាយរួចមកហើយ ។

**មាត្រា២.-** ធនាគារជាតិនៃកម្ពុជា មានភារកិច្ចចេញសេចក្តីប្រកាសមួយដើម្បីផ្សព្វផ្សាយពីលក្ខណៈ សំគាល់នៃក្រដាសប្រាក់គំរូថ្មីនេះ ។

**មាត្រា៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្ត-ក្រុងត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

---

**អនុក្រឹត្យលេខ ៣៥ អ.ន.ក្រ.បក**

**ស្តីពី**

**ការផ្តល់ប្រាក់បំណាច់បន្ថែមលើបៀវត្សរ៍ប្រចាំខែ សំរាប់នាយក នាយកដ្ឋាន ប្រធានស្ថាប័នឯករាជ ចំណុះផ្ទាល់ក្រសួងការពារជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំនិង ការប្រព្រឹត្តិទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៩អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហាឆ្នាំ ១៩៩៩ ស្ដីពីការផ្ដល់ប្រាក់ បំណាច់បន្ថែមលើបៀវត្សប្រចាំខែ សំរាប់អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងអគ្គនាយកដ្ឋានចំណុះក្រសួងការពារជាតិ ។
- បានឃើញអនុក្រឹត្យលេខ ៩៨អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកាឆ្នាំ ១៩៩៩ ស្ដីពីការតម្លើង បន្ថែមប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សា ព្រមទាំងមន្ត្រីស៊ីវិល និងកងកម្លាំងប្រដាប់អាវុធចាប់ពីថ្នាក់អនុរដ្ឋលេខា ធិការ ឡើងទៅ ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**មាត្រា១.-** ត្រូវ ទផ្ដល់ប្រាក់បំណាច់បន្ថែមលើបៀវត្សប្រចាំខែ សំរាប់នាយក នាយកដ្ឋាន ប្រធានស្ថាប័ន ឯករាជ្យចំណុះផ្ទាល់ក្រសួងការពារជាតិដូចតទៅ:

- ប្រាក់បំណាច់តំណាង
- ប្រាក់បំណាច់បដិសណ្ឋារកិច្ច
- ប្រាក់បំណាច់បេសកកម្ម
- ប្រាក់ឈ្នួលផ្ទះ ទឹក-ភ្លើង

**មាត្រា២ .-** ប្រាក់បំណាច់បន្ថែមលើបៀវត្សប្រចាំខែ ត្រូវបានកំណត់ដូចមាន តារាងខាងក្រោម :

| ប្រភេទប្រាក់បំណាច់ មុខតំណែង | ប្រាក់បំណាច់ តំណាង | ប្រាក់បំណាច់ បដិសណ្ឋារកិច្ច | ប្រាក់បំណាច់ បេសកកម្ម | ប្រាក់បំណាច់ ផ្ទះ ទឹក ភ្លើង | សរុប |
|---|---|---|---|---|---|
| នាយកដ្ឋាន ប្រធានស្ថាប័ន ឯករាជចំណុះផ្ទាល់ក្រសួងការពារ | ៣៦៧.៥០០ | ២៤៥.០០០ | ១៨៣.៧៥០ | ១៨៣.៧៥០ | ៩៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| ជាតិ :<br>១-នាយក<br>ខុទ្ទកាល័យក្រសួងការពារជាតិ<br>២-នាយក<br>នាយកដ្ឋាននយោបាយនិងផែនការ<br>៣-នាយក<br>នាយកដ្ឋាននីតិកម្ម<br>៤ -នាយក<br>នាយកដ្ឋានអធិការកិច្ច<br>៥-នាយក<br>នាយកដ្ឋានបុគ្គលិក<br>៦- នាយក<br>នាយកដ្ឋានភូមិសាស្ត្រ<br>៧- នាយក<br>វិទ្យាស្ថានយោធាកម្ពុជា<br>៨- ប្រធានស្ថាប័នអយ្យការ យោធា<br>៩- ប្រធានស្ថាប័នតុលាការ យោធា<br>ស្មើអនុរដ្ឋលេខាធិការ | | | | | |

**មាត្រា៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**